ព្រឹត្តិប័ត្រសារព័ត៌មាន

បទពិសោធន៍នៃសេវាថែទាំសុខភាពក្នុងតំបន់ថ្មី ចាប់ផ្តើមនៅកម្ពុជា ដើម្បីភ្ជាប់ទំនាក់ទំនងក្រុមគ្រួសារទៅកាន់ការថែទាំសុខភាពលំដាប់អន្តរជាតិ

ភ្នំពេញ ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២៦ - ធនាគារ មេយប៊ែង ខេមបូឌា សហការជាមួយ ក្រុមប្រឹក្សាទេសចរណ៍សុខភាពម៉ាឡេស៊ី (MHTC) នឹងរៀបចំកម្មវិធីពិព័រណ៍សុខភាព MH WellFest កម្ពុជា ២០២៦ នៅថ្ងៃទី៣ និងទី៤ ខែតុលា ឆ្នាំ២០២៦ នៅ បុរី ប៊ែង ហួត អេកូផាក រាជធានីភ្នំពេញ។

ក្រោមការគាំទ្រផ្លូវការពី ស្ថានទូតម៉ាឡេស៊ីប្រចាំប្រចាំទីក្រុងភ្នំពេញ ព្រឹត្តិការណ៍នេះនឹងប្រមូលផ្តុំមន្ទីរពេទ្យឈានមុខចំនួន១៤ មកពីប្រទេសម៉ាឡេស៊ី ដែលផ្តល់ឱកាសឱ្យអ្នកអ្នកចូលរួមនូវការជួបដោយផ្ទាល់ជាមួយក្រុមការងារថែទាំសុខភាពពីម៉ាឡេស៊ី គ្រូពេទ្យជំនាញឯកទេស និងព័ត៌មានស្តីពីការរៀបចំដំណើរទទួលសេវាថែទាំសុខភាពលំដាប់អន្តរជាតិ ព្រមទាំងដំណោះស្រាយហិរញ្ញវត្ថុ និងបទពិសោធន៍ដែលរៀបចំឡើងដោយពិសេសសម្រាប់ក្រុមគ្រួសារ។

កម្មវិធីពិព័រណ៍សុខភាព MH WellFest កម្ពុជា ២០២៦ ត្រូវបានបង្កើតឡើងក្រោមគំនិតសាមញ្ញមួយ៖ នៅពេលក្រុមគ្រួសារគិតគូអំពីអនាគតរបស់ខ្លួន សុខភាព ការត្រៀមខ្លួនផ្នែកហិរញ្ញវត្ថុ និងពេលវេលាប្រកបដោយអត្ថន័យជាមួយគ្នា គឺសុទ្ធតែជារឿងដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធ។ កម្មវិធីនេះនឹងផ្តល់ឱកាសដល់ក្រុមគ្រួសារកម្ពុជា និងអតិថិជនរបស់ធនាគារ មេយប៊ែង ក្នុងការស្វែងយល់ពីជម្រើសថែទាំសុខភាពនៅប្រទេសម៉ាឡេស៊ី ជួបជាមួយតំណាងមន្ទីរពេទ្យដោយផ្ទាល់ និងស្វែងយល់អំពីការគាំទ្រដែលមានសម្រាប់ដំណើរទទួលសេវាថែទាំសុខភាពលំដាប់អន្តរជាតិ។

អ្នកចូលរួមអាចជួបជាមួយក្រុមការងារថែទាំសុខភាពមកពីម៉ាឡេស៊ី ដើម្បីស្វែងយល់អំពីបរិក្ខារវិជ្ជសាស្ត្រ ជំនាញឯកទេស ជម្រើសក្នុងការថែទាំសុខភាព ការបង្ការ កម្មវិធីពិនិត្យសុខភាព ផែនការព្យាបាល និងការរៀបចំដំណើរព្យាបាលនៅបរទេស។ លើសពីនេះ កម្មវិធីពិគ្រោះ និងស្វែងយល់ពីសុខភាព (Wellness Discovery Hub) ក៏នឹងមានវត្តមាន ដែលជាវេទិកាចែករំលែកចំណេះដឹងសុខភាព និងការពិគ្រោះផ្ទាល់ជាមួយអ្នកឯកទេសពីម៉ាឡេស៊ីតាមការណាត់ជួបជាមុន ដើម្បីជួយឱ្យក្រុមគ្រួសារអាចធ្វើការសម្រេចចិត្តប្រកបដោយការយល់ដឹងកាន់តែច្បាស់សម្រាប់ខ្លួនឯង និងមនុស្សជាទីស្រឡាញ់។

លោក រ័ត្ន សោភ័ណ នាយកប្រតិបត្តិ និងនាយកប្រចាំប្រទេសរបស់ធនាគារ មេយប៊ែង ខេមបូឌា មានប្រសាសន៍ថា៖ «កម្មវិធីពិព័រណ៍សុខភាព MH WellFest កម្ពុជា ២០២៦ ឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរបស់ធនាគារ មេយប៊ែង ក្នុងការមានវត្តមានសម្រាប់ក្រុមគ្រួសារគ្រប់ពេលវេលាសំខាន់ៗក្នុងជីវិត។ ការសម្រេចចិត្តពាក់ព័ន្ធនឹងសុខភាព គឺជារឿងផ្ទាល់ខ្លួន ប៉ុន្តែវាក៏ពាក់ព័ន្ធយ៉ាងជិតស្និទ្ធទៅនឹងសុវត្ថិភាពគ្រួសារ ការត្រៀមខ្លួនផ្នែកហិរញ្ញវត្ថុ និងការកសាងអនាគតរួមគ្នាជាមួយមនុស្សជុំវិញខ្លួន។ ព្រឹត្តិការណ៍នេះនាំយកជំនាញថែទាំសុខភាពដែលគួរឱ្យទុកចិត្ត ដំណោះស្រាយហិរញ្ញវត្ថុជាក់ស្តែង និងបទពិសោធន៍សម្រាប់គ្រួសារមករួមបញ្ចូលគ្នាក្នុងវេទិកាតែមួយ ដែលបង្ហាញពីអត្ថន័យពិតនៃការផ្តល់លើសពីសេវាកម្មធនាគារធម្មតា»។

ក្រុមប្រឹក្សាទេសចរណ៍សុខភាពម៉ាឡេស៊ី (MHTC) ដែលប្រតិបត្តិការក្រោមការគ្រប់គ្រងរបស់ក្រសួងសុខាភិបាលម៉ាឡេស៊ី គឺជាស្ថាប័នដឹកនាំក្នុងការអភិវឌ្ឍ និងលើកកម្ពស់ប្រព័ន្ធអេកូឡូស៊ីនៃការធ្វើដំណើរសម្រាប់សេវាថែទាំសុខភាពរបស់ប្រទេសម៉ាឡេស៊ី។

លោក Dato' Suriaghandi Suppiah នាយកប្រតិបត្តិនៃក្រុមប្រឹក្សាទេសចរណ៍សុខភាពម៉ាឡេស៊ី (MHTC) មានប្រសាសន៍ថា៖ «ក្រុមប្រឹក្សាទេសចរណ៍សុខភាពម៉ាឡេស៊ី (MHTC) មានសេចក្តីរីករាយក្នុងការសហការជាមួយធនាការ មេយប៊ែង

ក្នុងការនាំយកបទពិសោធន៍នៃការថែទាំសុខភាពពីម៉ាឡេស៊ីឱ្យកាន់តែជិតជាមួយប្រជាជនកម្ពុជា។ ប្រទេសម៉ាឡេស៊ីផ្តល់ជូននូវប្រព័ន្ធថែទាំសុខភាពដ៏រឹងមាំ ដែលគាំទ្រដោយអ្នកជំនាញឯកទេស គុណភាពសេវាកម្ម ជម្រើសសុខភាពដែលងាយស្រួលទទួលបាន និងបទពិសោធន៍អ្នកជំងឺដែលស្តែងចេញពីវប្បធម៌នៃបដិសណ្ឋារកិច្ចរបស់យើង។ កម្មវិធីពិព័រណ៍សុខភាព MH WellFest កម្ពុជា ២០២៦ នឹងផ្តល់ឱកាសឱ្យអ្នកចូលរួមក្នុងការស្វែងយល់ពីចំណុចសំខាន់ទាំងនេះដោយផ្ទាល់ ជួបជាមួយអ្នកផ្តល់សេវាថែទាំសុខភាព ព្រមទាំងទំនុកចិត្តកាន់តែខ្លាំងក្នុងការរៀបចំដំណើរថែទាំសុខភាពរបស់ខ្លួនលំដាប់អន្តរជាតិ»។

ក្រៅពីការស្វែងយល់លើផ្នែកថែទាំសុខភាព កម្មវិធីកម្សាន្ត និងចែករំលែកចំណេះដឹងអំពីសុខភាព (WellFest Live) នឹងបង្កើតបរិយាកាសគ្រួសារក៏កក់ក្តៅតាមរយៈសកម្មភាពកុមារ ការលេងកម្សាន្តសម្រាប់គ្រួសារ ការសម្តែងផ្ទាល់ ម្ហូបអាហារម៉ាឡេស៊ី បទពិសោធន៍នៃការរស់នៅ គំនិតសម្រាប់ការធ្វើដំណើរ និងការតាំងបង្ហាញពីមន្ទីរពេទ្យដែលជាដៃគូផ្សេងៗ។

ចំណែក កម្មវិធីរត់ដើម្បីសុខភាព (WellFest Run) ដែលមានចម្ងាយ ៥គីឡូម៉ែត្រ ឬ ១០គីឡូម៉ែត្រ ក្រោមប្រធានបទ «គ្រប់ជំហានដើម្បីមនុស្សជាទីស្រលាញ់» នឹងនាំធ្វើឱ្យអ្នកចូលរួមទាំងអស់ ក្រុមគ្រួសារ និងសហគមន៍មកជួបជុំគ្នាពោរពេញដោយសកម្មភាពក្នុងការរស់នៅ និងសុខភាពល្អ ស្របតាមគោលគំនិត «Healing Meets Hospitality» ដែលជាផ្នែកមួយនៃ Malaysia Year of Medical Tourism 2026។

ការចូលរួមរបស់ធនាគារ មេយប៊ែង នឹងពង្រីកកិច្ចសន្ទនាអំពីសុខភាពឱ្យទៅជាការរៀបចំផែនការទ្រព្យសម្បត្តិ និងការការពារហិរញ្ញវត្ថុសម្រាប់គ្រួសារផងដែរ។ អ្នកចូលរួមទាំងអស់អាចស្វែងយល់អំពីប័ណ្ណរបស់ធនាគារ មេយប៊ែង ដំណោះស្រាយការទូទាត់ឆ្លងដែនជម្រើសបង់រំលស់ EzyPay កញ្ចប់ធានារ៉ាប់រង និងដំណោះស្រាយហិរញ្ញប្បទានដែលអាចគាំទ្រដល់ការរៀបចំផែនការសុខភាព ការព្យាបាល ការធ្វើដំណើរ និងគោលដៅគ្រួសាររយៈពេលវែង។

ប័ណ្ណរបស់ធនាគារ មេយប៊ែង ក៏នឹងភ្ជាប់អតិថិជនជាមួយការផ្តល់ជូនពិសេសពីមន្ទីរពេទ្យ ស្បា គ្លីនិក ភោជនីយដ្ឋាន ហាងទំនិញ និងការផ្តល់ជូនសម្រាប់តម្រូវការប្រចាំថ្ងៃក្នុងប្រទេសម៉ាឡេស៊ី ដើម្បីធ្វើឱ្យបទពិសោធន៍ធ្វើដំណើរទៅប្រទេសម៉ាឡេស៊ីសម្រាប់ការសម្រាកព្យាបាល និងពេលវេលាជាមួយគ្រួសារ កាន់តែងាយស្រួល និងប្រកបដោយផាសុកភាព។

ដោយមានបុរី ប៉ែង ហួត ជាដៃគូទីតាំងរៀបចំព្រឹត្តិការណ៍ កម្មវិធីពិព័រណ៍សុខភាព MH WellFest កម្ពុជា ២០២៦ នឹងនាំយកការថែទាំសុខភាពពីប្រទេសម៉ាឡេស៊ី ទំនុកចិត្ត និងបទពិសោធន៍សម្រាប់គ្រួសារ មកជួបជុំគ្នានៅក្នុងទីតាំងតែមួយ ដើម្បីជួយឱ្យក្រុមគ្រួសារកម្ពុជាស្វែងយល់ពីជម្រើសថែទាំសុខភាពលំដាប់អន្តរជាតិដោយមានភាពច្បាស់លាស់ និងទំនុកចិត្តកាន់តែខ្ពស់។

សូមអញ្ជើញសាធារណជន និងអតិថិជនរបស់ធនាគារ មេយប៊ែងទាំងអស់ ចូលរួម កម្មវិធីពិព័រណ៍សុខភាព MH WellFest កម្ពុជា ២០២៦ នៅថ្ងៃទី៣ និងទី៤ ខែតុលា ឆ្នាំ២០២៦ នៅ បុរី ប៉ែង ហួត អេកូផាកខាងមុខនេះ។ អ្នកចូលរួមទាងអស់ អាចជួបពិភាក្សាជាមួយក្រុមការងារថែទាំសុខភាពពីម៉ាឡេស៊ី ស្វែងយល់ពីជម្រើសថែទាំសុខភាព សេវាឯកទេស និងបទពិសោធន៍ Healing Meets Hospitality តាមរយៈសកម្មភាពទាក់ទងនឹងសុខមាលភាព របៀបរស់នៅ និងសកម្មភាពសហគមន៍ពេញមួយចុងសប្តាហ៍។

****